# មជ្ឈមណ្ឌលបេតិកភណ្ឌ



មជ្ឈមណ្ឌលបេតិកភណ្ឌ ជាសាខារបស់អង្គការសិល្បៈខ្មែរអមតៈ ប្រចាំខេត្តសៀមរាប។ មជ្ឈមណ្ឌលធ្វើការគាំទ្របេសកកម្មរបស់អង្គការក្នុងនាមជាកត្តាជំរុញនៅក្នុងវិស័យសិល្បៈដ៏រស់រវើកដែលញ៉ាំងចិត្តអ្នកជំនាន់ថ្មី។ មជ្ឈមណ្ឌលផ្តោតសំខាន់ លើការពង្រឹងសិល្បៈនិងវប្បធម៌ដែលកំពុងរស់នៅជាមួយជីវភាពប្រចាំថ្ងៃរបស់ប្រជាជន រាប់បញ្ចូលតាំងពីតន្ត្រី ពិធីសក្ការៈនានា សិប្បកម្ម ម្ហូប និងវប្បធម៌ទំនាក់ទំនងគ្នាក្នុងសង្គមជាដើម។ ប៉ុន្តែទម្រង់សិល្បៈទស្សនីយភាព គឺជាអាទិភាពរបស់មជ្ឈមណ្ឌល។

## បេសកកម្មរបស់មជ្ឈមណ្ឌលបេតិកភណ្ឌ

*យើងធ្វើការពង្រឹងសិល្បៈនិងវប្បធម៌រស់ ដើម្បីលើកតម្កើងប្រទេសកម្ពុជា ជាពិសេសខេត្តសៀមរាប តាមរយៈ គុណតម្លៃនៃវប្បធម៌ គុណតម្លៃនៃភាពច្នៃប្រឌិត និងគុណតម្លៃនៃសេដ្ឋកិច្ច។*

**គោលដៅរបស់យើងរួមមាន៖**

១. ផ្សព្វផ្សាយដល់ប្រជាជនទាំងក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ឲ្យស្គាល់ខេត្តសៀមរាប ថាជាមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងជាមួយបេតិកភណ្ឌរស់ក្នុងប្រទេសកម្ពុជា។

២. ធានាឲ្យបានថា សិល្បករកម្ពុជានៅខេត្តសៀមរាប មានជំនាញ និងឱកាសដែលអាចឲ្យពួកគេទទួលបានប្រាក់ចំណូលប្រកបដោយនិរន្តរភាពតាមរយៈជំនាញសិល្បៈរបស់ខ្លួន។

៣. បង្កើនការយល់ដឹងអំពីបេតិកភណ្ឌរស់ នៅកម្ពុជា តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល មូលនិធិ ធនធាន និងបណ្តាញដល់អ្នកស្រាវជ្រាវ ជាពិសេសអ្នកស្រាវជ្រាវកម្ពុជាដែលកំពុងផុសឡើងនាពេលបច្ចុប្បន្ន។

៤. បង្កើនការយល់ដឹងអំពីគ្នាទៅវិញទៅមក និងលើកកម្ពស់វប្បធម៌ចែករំលែកដោយជំរុញឲ្យមានការផ្លាស់ប្តូរវិស័យសិល្បៈ និងកិច្ចពិភាក្សាក្នុងតំបន់អាស៊ីពិសេសតំបន់ទន្លេមេគង្គ។

៥. រក្សាឲ្យបាននូវសិល្បៈរស់ទាំងឡាយសម្រាប់កម្ពុជាបច្ចុប្បន្ន តាមរយៈការជំរុញឲ្យមានការបង្កើតថ្មីក្នុងចំណោមសិល្បករប្រពៃណី។





## ព័ត៌មានបន្ថែម៖

**សុង សេង** នាយកមជ្ឈមណ្ឌលបេតិកភណ្ឌ។ សម្រាប់ព័ត៌មានបន្ថែម ឬចង់ចូលរួមជាមួយពួកយើង សូមទាក់ទងទៅកាន់ seng@cambodianlivingarts.org ។

# សកម្មភាពមជ្ឈមណ្ឌលបេតិកភណ្ឌ

សកម្មភាពមជ្ឈមណ្ឌលបេតិកភណ្ឌ គឺអនុវត្តតាមកម្មវិធីស្នូលរបស់អង្គការសិល្បៈខ្មែរអមតៈ រួមមានការផ្តល់ការណែនាំ ភាពជាអ្នកដឹកនាំ និងជំនាញការនានាសម្រាប់គម្រោងបេតិកភណ្ឌរស់កម្ពុជា។ មជ្ឈមណ្ឌលដើរតួជាអ្នកដឹកនាំគម្រោងពាក់ព័ន្ធនឹងសិល្បទស្សនីយភាពក្នុងខេត្តសៀមរាប។ សកម្មភាពរបស់យើងរួមមាន៖



## កម្មវិធីអភិវឌ្ឍន៍សិល្បៈ

កម្មវិធីសិក្ខាសាលា ការគាំទ្របង្កើតស្នាដៃថ្មី ការសម្តែង មហោស្រព និងមូលនិធិខ្នាតតូច។ ក្នុងខែមករា ២០១៧ យើងបានផ្តល់ការគាំទ្រដល់សិល្បករស្ត្រីមកពីក្រុមសំឡេងអង្គរក្នុងការបង្កើតស្នាដៃថ្មី “ព្រលឹងស្គរជ័យ”។ ក្នុងខែកក្កដា ២០១៧ យើងរៀបចំគម្រោងនិវាសនដ្ឋានផ្នែកតន្ត្រីសម្រាប់សិល្បករប្រពៃណី រៀនបង្កើតស្នាដៃថ្មី។ ក្នុងពេលដ៏ខ្លីខាងមុខ យើងនឹងប្រកាសផ្តល់មូលនិធិខ្នាតតូច ដល់សិល្បករ និងសហគមន៍សិល្បៈសម្រាប់គម្រោងសិល្បៈថ្មីៗ។

## កម្មវិធីចំណេះដឹង បណ្តាញ និងគោលនយោបាយវប្បធម៌

យើងជួយសិល្បករ និងអ្នកបម្រើការក្នុងវិស័យសិល្បៈក្នុងការកសាងបណ្តាញ និងចែករំលែកចំណេះដឹងអំពីបេតិកភណ្ឌរស់។ ក្នុងខែវិច្ឆិកា ២០១៦ យើងបានរៀបចំកិច្ចប្រជុំតុមូលតុក្កតាកម្ពុជា។ យើងក៏បានចូលរួម និងសម្របសម្រួលសិល្បករទៅចូលរួមកម្មវិធីថ្នាក់តំបន់ និងពិភពលោក ដូចជា សន្និសីទក្រុមប្រឹក្សាតន្ត្រីប្រពៃណីអន្តរជាតិ (ICTM) ផងដែរ។ ក្នុងពេលអនាគត យើងនឹងរៀបចំវគ្គបណ្តុះបណ្តាលជំនាញស្រាវជ្រាវ កិច្ចប្រជុំតុមូលសម្រាប់អ្នកស្រាវជ្រាវ និងនិវាសនដ្ឋានផ្នែកស្រាវជ្រាវនៅសៀមរាប ដើម្បីជួយដល់ការងារស្រាវជ្រាវអំពីបេតិកភណ្ឌរស់។






## សហគ្រាសសិល្បៈខ្មែរអមតៈ

យើងរៀបចំការសម្តែង និងបទបង្ហាញសិល្បៈជាលក្ខណៈឯកជននានា ដើម្បីបង្កើតឱកាសការងារដល់សិល្បករក្នុងស្រុកជាមួយនឹងប្រាក់ចំណូលប្រកបដោយនិរន្តរភាពតាមរយៈជំនាញសិល្បៈរបស់ខ្លួន។ ហើយសិល្បករក៏មានឱកាសបង្ហាញសមត្ថភាព និងកសាងទំនាក់ទំនងជាមួយទស្សនិកជនផងដែរ។

**មជ្ឈមណ្ឌលបេតិកភណ្ឌ៖** វត្តរាជបូណ៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប
| cambodianlivingarts.org/heritage-hub | 063 967 032